ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...៦៦...សសរ..

# សេចក្តីសម្រេច
## ស្តីពី
## ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល



www.pheakdeylaw.com

## សម្រេច

**ប្រការ១ .-**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តកណ្តាល** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** | អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ | សមាជិក |
| ២. ឯកឧត្តម **រស់ វណ្ណា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានអគ្គនាយកកាំសាប | សមាជិក |
| ៣. ឯកឧត្តម **គីម សុភ:** | នាយកខុទ្ទកាល័យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. ឯកឧត្តម **ហេង រតនា** | អគ្គនាយកមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា | សមាជិក |
| ៥. ឯកឧត្តម **កែវ បេងវឌ្ឍន៍** | អគ្គនាយកនៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. ឯកឧត្តម **ម៉ី វ៉ាន់** | អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. ឯកឧត្តម **ម៉ិញ បានកុសល** | អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨. លោកជំទាវ **លឹម មុំ** | អគ្គនាយិកានៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន | សមាជិក |
| ៩. ឯកឧត្តម **ទេស រុក្ខាផល** | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅគ្រប់មុខសញ្ញា | សមាជិក |
| ១០. ឯកឧត្តម **ឈាង រ៉ា** | អគ្គនាយកមន្ទីរពេទ្យកាល់ម៉ែតក្រសួងសុខាភិបាល | សមាជិក |
| ១១. ឯកឧត្តម **ជាម និមល** | ទីប្រឹក្សាក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២. ឯកឧត្តម **ប៉ែន សំអាត** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |



www.pheakdeylaw.com

| | | |
|---|---|---|
| ១៣. លោក **បុង ប៊ុនហួន** | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៤. លោក **ឡៅ មិញសីហា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១៥. ឯកឧត្តមឧត្តមសេនីយ៍ឯក **ជឹម សុខ** | នាយរងសេនាធិការចម្រុះ និងជានាយកទីចាត់ការបុគ្គលិកនៃអគ្គបញ្ជាការដ្ឋាន | សមាជិក |
| ១៦. លោក **អ៊ុំ សីហា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៧. លោក **អ៊ុំ ភូមិរ៉ូ** | អគ្គនាយករងមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា | សមាជិក |
| ១៨. លោក **ជាប ដារុធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៩. លោក **អ៊ុយ ធួន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ ក្រសួងព័ត៌មាន | សមាជិក |
| ២០. លោក **ប៉ែន ធីវុឌ្ឍ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២១. លោក **ខាន់ វណ្ណៈ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២២. លោកស្រី **កុច មារតី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ក្រសួងព័ត៌មាន | សមាជិក |
| ២៣. លោក **កង សុសាទី** | អគ្គនាយករងនៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ | សមាជិក |
| ២៤. លោក **គង់ វណ្ណា** | ទីប្រឹក្សានៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ២៥. ឧត្តមសេនីយ៍ទោ **ពូ សាប៊ុតឌី** | មេបញ្ជាការរង និងជានាយសេនាធិការយោធភូមិភាគពិសេស | សមាជិក |
| ២៦. លោក **វ៉ាន់ ពុទ្ធិពល** | អនុប្រធាននាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |



www.pheakdeylaw.com

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តកណ្តាល និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០១៤

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ស ខេង

កន្លែងទទួល:

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -គ្រប់ក្រសួង ស្ថាប័ន
- -រដ្ឋបាលថ្នាក់ក្រោមជាតិ
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com